ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ

លេខ : ០៧១៦/១០ ក.អ.ជ

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០

**រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**ជម្រាបមក**

**លោក ហៀក ថ្វែន តំណាងសហគមន៍ជនជាតិដើមភាគតិច ទំពួន**

**ភូមិសមុទ្រលើ ឃុំសេដា ស្រុកលំផាត់**

**កម្មវត្ថុ:** ស្តីពីការទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ទំពួន ភូមិសមុទ្រលើ ឃុំសេដា ស្រុកលំផាត់

**យោង:**
- លិខិតចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ស្តីពីការស្នើសុំទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ទំពួន ភូមិសមុទ្រលើ របស់លោក ហៀក ថ្វែន តំណាងសហគមន៍។
- លិខិតលេខ ១៨៣/១០ ល.អ.ខ ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ២០១០ ស្តីពីការទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ទំពួន ភូមិសមុទ្រលើ របស់អភិបាល នៃគណៈអភិបាលខេត្តរតនគិរី។
- លទ្ធផលវាយតម្លៃអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ទំពួន ភូមិសមុទ្រលើ របស់ក្រុមការងារនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច នៃក្រសួងអភិវឌ្ឍន៍ជនបទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមលោកជ្រាបថា ក្រសួងអភិវឌ្ឍន៍ជនបទយល់ព្រមទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ទំពួន ភូមិសមុទ្រលើ ឃុំសេដា ស្រុកលំផាត់ ខេត្តរតនៈគិរី តាមសំណើ។ សហគមន៍ជនជាតិដើមភាគតិច ទំពួន ភូមិសមុទ្រលើ អាចប្រើប្រាស់លិខិតទទួលស្គាល់អត្តសញ្ញាណនេះ ក្នុងសកម្មភាពបម្រើដល់ផលប្រយោជន៍រួមរបស់សហគមន៍ ផលប្រយោជន៍សង្គម និងផលប្រយោជន៍ជាតិតាមការចាំបាច់ស្របតាមគោលនយោបាយ ច្បាប់ បទបញ្ញា និងលិខិតបទដ្ឋានទាំងឡាយ នៃព្រះរាជាណាចក្រកម្ពុជា។

សូមលោក ទទួលនូវសេចក្តីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

ព្រះរាជាណាចក្រកម្ពុជា ក្រសួងអភិវឌ្ឍន៍ជនបទ

ជា សុផារ៉ា

*ចម្លងជូន*

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-ក្រសួងទេសចរណ៍

"ដើម្បីជូនជ្រាប"

-សាលាខេត្តរតនគិរី

-មន្ទីរអភិវឌ្ឍន៍ជនបទខេត្តរតនគិរី

"ដើម្បីមុខការ"

-ឯកសារកាលប្បវត្តិ